# ដានជើងលើឆ្នេរ

បាទាឈានឈាយាត្រាទៅ សល់នៅក្រឡេវដៅលើឆ្នេរ
ស្នាមដាមដិតដានជើងទាំងទ្វេ បីដូចគេឆ្លាក់ជាក់ឥតក្លែង។
ដានជើងពិតៗស្ថិតស្រស់ៗ ប្រៀបបានគេបោះត្រាយ៉ាងស្តែង
ស្នាមបាតស្នាមម្រាមល្អទន្ទេង គេឯងបានយល់រាល់អាត្មា។
ស្រាប់តែរលកបោកមកដល់ ដូចកល់មួយព្រិចភ្នែកសោះណា
ដានជើងរលុបបង់អសារ រលាយអាត្មាគ្មានសល់អ្វី។
ជើងមេឃដេកស្ងៀមឥតខ្វល់ខ្វាយ ឆ្នេរសណ្ដូកកាយធ្វើវាហី
រលកកញ្ជ្រោកបោកម្ដេចក្ដី សាគរឥតភ័យឥតបីគិត។
អាស្សូរដល់ដានជើងលើឆ្នេរ មានរូបរាងដែរតែពុំស្ថិត
ពុំស្ថេរចេរលង់បង់អស់ឫទ្ធិ ព្រោះដ្បិតរលកបោកកម្ទាយ។

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី